ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

# ការសិក្សាបឋម ស្តីពីប្រព័ន្ធអំប៊ុស្មាន់ និង ការទទួលពាក្យបណ្តឹង នៅកម្ពុជា

អង្គភាពគ្រប់គ្រងគម្រោង
ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
កុម្ភៈ ២០០៩

# មាតិកា


| | |
|---|---|
| ១. សេចក្តីផ្តើម | ២ |
| ២. ការសិក្សាបឋម | ៣ |
| ២.១ វិធីស្រាវជ្រាវ | ៣ |
| ២.២ ការិយាល័យដែលបានជួយសម្ភាស | ៣ |
| ២.៤ កិច្ចសម្ភាសជាមួយទីភ្នាក់ងាររដ្ឋាភិបាល | ៥ |
| ២.៤.២ អាជ្ញាធរជាតិដើម្បីដោះស្រាយវិវាទដីធ្លី | ៦ |
| ២.៤.៣ ការិយាល័យ ដោះស្រាយវិវាទនៅក្រសួងពាណិជ្ជកម្ម | ៨ |
| ២.៤.៨ ក្រសួងទំនាក់ទំនងសភា ព្រឹទ្ធសាភា និងអធិការកិច្ច | ១២ |
| ២.៤.៩ អង្គភាពប្រឆាំងអំពើពុករលួយ | ១៣ |
| ២.៥ កិច្ចសម្ភាសជាមួយអង្គការក្រៅរដ្ឋាភិបាល | ១៤ |
| ៣. ទស្សនាទានអំពីអំប៊ូស្មាន់ | ២០ |
| ៣.១ និយមន័យ | ២០ |
| ៣.២ លក្ខណៈវិនិច្ឆ័យរបស់អំប៊ូស្មាន់ | ២០ |
| ៣.៣ តួនាទី និងមុខងាររបស់អំប៊ូស្មាន់ | ២១ |
| ៣.៤ ភាពផ្សេងៗនៃប្រព័ន្ធអំប៊ូស្មាន់ | ២២ |
| ៣.៥ ឈ្មោះផ្សេងៗដែលបានប្រើប្រាស់សម្រាប់អំប៊ូស្មាន់ | ២៣ |
| ៤. គំនិតដំបូងៗ "អំប៊ូស្មាន់" នៅកម្ពុជា | ២៥ |
| ៤.១ ជំរើសទី ១ | ២៥ |
| ៤.២ ជំរើសទី ២ | ២៥ |
| ៤.៣ ជំរើសទី ៣ | ២៦ |
| ៤.៤ ឈ្មោះការិយាល័យទទួលពាក្យបណ្តឹង | ២៦ |
| ៥ ការសង្កេតចុងក្រោយ | ២៧ |

# ១. សេចក្តីផ្តើម

ការកើនឡើងគួរឱ្យកត់សំគាល់ នៃអំណាចនីតិបញ្ញត្តិ និងការងាររដ្ឋបាលសាធារណៈ ដោយសារតែជីវភាពរស់នៅរបស់សង្គមសេដ្ឋកិច្ចកាន់តែរីកស្ទុះស្ទាញទៅនោះ បានធ្វើឱ្យទំនាក់ទំនងរវាងរដ្ឋបាលសាធារណៈ និងប្រជាពលរដ្ឋកាន់តែមានភាពលំបាកឡើង។ ប្រជាពលរដ្ឋត្រូវប្រឈមជាមួយនឹង រចនាសម្ព័ន្ធបែបការិយាល័យធិបតេយ្យ និងការខ្វះខាតដ៏ខ្លាំងក្លាផ្នែកតម្លាភាព។ ទាំងនេះ ជាលទ្ធផលបង្កើតឱ្យមានភាពមិនជឿជាក់ ភាពខ្លាចរអា និងរាថយរបស់ប្រជាពលរដ្ឋ។ ដោយមើលឃើញដូច្នេះ រាជរដ្ឋាភិបាលបានសម្រេចរៀបចំឱ្យមានជាឧបករណ៍ច្បាប់ដ៏មានប្រសិទ្ធិភាពផ្សេងៗ ដើម្បីការពារប្រជាពលរដ្ឋ និងកែលម្អទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋបាលសាធារណៈ។

ឧបករណ៍មួយដែលអាចអនុវត្តបានសម្រាប់ទិសដៅនេះ គឺការអនុវត្តនូវប្រព័ន្ធអំប៊ូស្មាន់ថ្នាក់ជាតិ ដ៏ទូលំទូលាយមួយ។ អំប៊ូស្មាន់ អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការពិនិត្យ តាមដាន ការអនុវត្តការងាររបស់មន្ត្រីរាជការ ដើម្បីធ្វើឱ្យ រដ្ឋបាលសាធារណៈមានគណនេយ្យភាព តម្លាភាព និងការឆ្លើយតបចំពោះប្រជាពលរដ្ឋកាន់តែខ្លាំងឡើង។ នៅឆ្នាំ២០០៣ គណៈរដ្ឋមន្ត្រី បានពិចារណាដាក់បញ្ចូលការអនុវត្តប្រព័ន្ធអំប៊ូស្មាន់ ទៅក្នុងយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ហើយនៅឆ្នាំ ២០០៥ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានរៀបចំការងារនេះនៅក្នុងសកម្មភាពជាអាទិភាព ១.៦.១ នៃផែនការសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ។ នៅក្នុងឆ្នាំ ២០០៥ នេះដែរ មន្ត្រីអំប៊ូស្មាន់ ត្រូវបានធ្វើការបោះឆ្នោតជ្រើសរើសនៅក្នុងស្រុកបាត់ដំបង និងស្រុកសៀមរាប នៅក្នុងគម្រោងសាកល្បង អាស៊ី អឺប ៣ (ASIA URB III) "ការលើកដំកើងរដ្ឋបាលក្រុង"។

នៅខែមិថុនា ឆ្នាំ២០០៥ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ របស់អង្គការសហប្រតិបត្តិការហ្សីធីហ្សេត (GTZ ARDP) បានព្រមព្រៀងគ្នាអនុវត្តនូវគម្រោងមួយដើម្បីធ្វើការសិក្សាបញ្ចូល និងរៀបចំក្របខ័ណ្ឌទស្សនាទានមួយសម្រាប់អំប៊ូស្មាន់នៅកម្ពុជា។ ដំណាក់កាលនៃការអនុវត្តគម្រោងនេះមានដូចខាងក្រោម:

១. ការសិក្សាវាយតំលៃអំពីប្រព័ន្ធអំប៊ូស្មាន់នៅបាត់ដំបង និងសៀមរាប និងការិយាល័យទទួលពាក្យបណ្តឹងផ្សេងទៀតនៅកម្ពុជា

២. ការជួបពិគ្រោះយោបល់ជាមួយតំណាងក្រសួង តំណាងសង្គមស៊ីវិលនិង ដៃគូអភិវឌ្ឍន៍មួយចំនួន

៣. ទស្សនៈកិច្ចសិក្សាក្នុងបណ្តាប្រទេសអាស៊ីមួយចំនួន ដើម្បីស្វែងយល់ដកពិសោធន៍ពីគំរូអំប៊ូស្មាន់ផ្សេងៗ

៤. រៀបចំបញ្ចប់ឯកសារក្របខ័ណ្ឌសម្រាប់អំប៊ូស្មាន់កម្ពុជា

សកម្មភាពដំបូងរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្នុងការការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌទស្សនាទានអំប៊ូស្មាន់សម្រាប់កម្ពុជា ត្រូវបានសង្ខេបនៅក្នុងរបាយការណ៍នេះ។ របាយការណ៍នេះរួមបញ្ចូលៈ

១. ការសិក្សាអង្កេតអំប៊ូស្មាន់បាត់ដំបង និងសៀមរាប រួមទាំងការិយាល័យទទួលបណ្តឹងមួយផ្សេងទៀត

២. ទិដ្ឋភាពទូទៅអំពីអំប៊ូស្មាន់

៣. ជំរើសសម្រាប់កម្ពុជា។

## ២. ការសិក្សាបឋម

## ២.១ វិធីស្រាវជ្រាវ

ការសិក្សាបឋម អំពីការិយាល័យទទួលពាក្យបណ្តឹងនៅក្នុងរដ្ឋបាលសាធារណៈកម្ពុជា ត្រូវបានធ្វើឡើងដោយការចុះធ្វើបទសម្ភាសផ្សេងៗ។ អ្នកដែលត្រូវបានសម្ភាសជាទូទៅគឺ ជាប្រធាននាយកដ្ឋាន ឬអនុប្រធានអង្គភាពដែលពាក់ព័ន្ធ។

ជាងនេះទៅទៀត ក្រុមការងារអនុវត្តគម្រោងនេះ បានចុះធ្វើបទសម្ភាសជាមួយតំណាងអង្គការក្រៅរដ្ឋាភិបាល ដែលបានជួយកម្ពុជាទាក់ទងនឹងវិវាទផ្នែករដ្ឋបាលនេះដែរ។ ការធ្វើបទសម្ភាស ត្រូវបានធ្វើឡើងចាប់តាំងពីខែសីហា ដល់ខែធ្នូ ឆ្នាំ២០០៨។ រយៈពេលមធ្យមនៃការធ្វើបទសម្ភាសនីមួយៗ មានពី ១ ម៉ោង ទៅ ១ ម៉ោងកន្លះ។

## ២.២ ការិយាល័យដែលបានជួយសម្ភាស

ជារួមមានស្ថាប័នចំនួន ១០ ដែលបានជួបសម្ភាសក្នុងនោះ ស្ថាប័នចំនួន ៨ ជាក្រសួង និងការិយាល័យរដ្ឋបាលសាធារណៈ ហើយស្ថាប័ន ២ ផ្សេងទៀត មិនមែនជាស្ថាប័នរដ្ឋ។ ជាមួយគ្នានេះដែរ ស្ថាប័នមួយចំនួនមិនទាន់អាចជួបប្រជុំបាន មានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាជាដើម ដោយសារតែមានការរៀបចំរចនាសម្ព័ន្ធថ្មី របស់រដ្ឋាភិបាល នៅខែកញ្ញា ឆ្នាំ២០០៨ និងបញ្ហាជាប់រវល់ផ្សេងទៀត។

**បញ្ជីស្ថាប័នដែលបានជួបៈ**

ស្ថាប័នរដ្ឋៈ

- អំប៊ូស្មាន់នៅស្រុកបាត់ដំបង

- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- ក្រសួងពាណិជ្ជកម្មនាយកដ្ឋាននីតិកម្ម
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (កម្មសិទ្ធឧស្សាហកម្ម ប៉ាតង់...)
- គម្រោង CCJAP III អំប៊ូស្មាន់សម្រាប់នគរបាល
- ក្រសួងយុត្តិធម៌ គម្រោងសិទ្ធិទទួលបានយុត្តិធម៌
- ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- អង្គភាពប្រឆាំងអំពើពុករលួយ

ស្ថាប័នមិនមែនរដ្ឋ:

- ការិយាល័យឧត្តមស្នងការជាន់ខ្ពស់សម្រាប់សិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ
- អង្គការ អាដហុក

## ២.៤ កិច្ចសម្ភាសជាមួយទីភ្នាក់ងាររដ្ឋាភិបាល

### ២.៤.១ ការិយាល័យប្រជាពលរដ្ឋនៅស្រុកបាត់ដំបង

**ការិយាល័យប្រជាពលរដ្ឋ** នៅស្រុកបាត់ដំបង ត្រូវបានបោះឆ្នោតជ្រើសរើសនៅរដូវក្តៅឆ្នាំ ២០០៥ សម្រាប់អាណត្តិ ៣ ឆ្នាំ ដែលផ្អែកលើប្រកាសលេខ ៧៩០ ស្តីពីរចនាសម្ព័ន្ធ និងការគ្រប់គ្រងការិយាល័យប្រជាពលរដ្ឋនៅស្រុកបាត់ដំបង ខេត្តបាត់ដំបង របស់ក្រសួងមហាផ្ទៃ។

ការិយាល័យប្រជាពលរដ្ឋនេះ ជាផ្នែកមួយនៃរចនាសម្ព័ន្ធរដ្ឋបាលថ្មីថ្នាក់ស្រុក នៅខេត្តបាត់ដំបង។ ការិយាល័យប្រជាពលរដ្ឋ ដើរតួនាទីពិនិត្យមើលការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យផ្សេងទៀតនៅក្នុងរដ្ឋបាលស្រុកបាត់ដំបង។ ការិយាល័យប្រជាពលរដ្ឋ ត្រូវមានវត្តមាននៅក្នុងការិយាល័យច្រកចេញចូល តែមួយយ៉ាងតិចចំនួន ១២ ម៉ោងក្នុងមួយសប្តាហ៍។

ការិយាល័យប្រជាពលរដ្ឋ គឺជាអ្នកតំណាងអព្យាក្រឹត្យរបស់ប្រជាពលរដ្ឋ ដែលមានតួនាទីស្វែងរកដំណោះស្រាយដែលអាចទទួលយកបានសម្រាប់ប្រជាពលរដ្ឋ និងសហគ្រិន។ ដើម្បីសម្រេចបាននូវគោលដៅនេះ ការិយាល័យប្រជាពលរដ្ឋ មានអំណាចដូចខាងក្រោម:

- ការិយាល័យប្រជាពលរដ្ឋ មានសិទ្ធិពិនិត្យរាល់លិខិតស្នាមដែលពាក់ព័ន្ធ
- បើសិនជាការសម្រុះសម្រួលរវាងប្រជាពលរដ្ឋ និងមន្ត្រីរដ្ឋបាល មិនបានជោគជ័យទេ ការិយាល័យប្រជាពលរដ្ឋ មានសិទ្ធិបញ្ជូនឯកសាររួមទាំងអនុសាសន៍ផ្សេងៗទៅអភិបាលស្រុកដើម្បីពិនិត្យ និងសម្រេច
- បណ្តឹងពាក់ព័ន្ធការបំពេញការងាររបស់អភិបាលស្រុក ត្រូវបញ្ជូនទៅថ្នាក់អភិបាលខេត្ត ដើម្បីដោះស្រាយ

ការិយាល័យប្រជាពលរដ្ឋ ស្ថិតនៅជាន់ទីមួយនៃរដ្ឋបាលស្រុកបាត់ដំបង។ ទីតាំងនេះ ធ្វើឱ្យមានភាពមិនងាយស្រួលក្នុងការទាក់ទង និងមិនសូវមើលឃើញ។ ផ្លាកសញ្ញានៃការិយាល័យនេះ ក៏មិនបានដាក់ឱ្យមើលឃើញច្បាស់ដែរ។

ការវាយតម្លៃ និងតាមដានពីអាជ្ញាធរមូលដ្ឋានលើការងាររបស់ ការិយាល័យប្រជាពលរដ្ឋ នៃការិយាល័យច្រកចេញចូលតែមួយនេះ ត្រូវបានបញ្ជាក់ថា ទទួលបានជោគជ័យ ប៉ុន្តែមានប្រជាពលរដ្ឋមួយចំនួនតិចប៉ុណ្ណោះដែលបាលចូលមកការិយាល័នេះ ដើម្បីប្តឹងពីការបំពេញការងាររបស់រដ្ឋបាល។ ក្នុងរយៈពេល ៣ ឆ្នាំ មកនេះ មានបណ្តឹងចំនួនតែ ២ ប៉ុណ្ណោះ ដែលបានចុះក្នុងបញ្ជី និងបានដោះស្រាយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មាន

បណ្ដឹងមួយចំនួនទៀតដែលប្ដឹងដោយប្រជាពលរដ្ឋដែរ ប៉ុន្តែជាបណ្ដឹងដែលមិនស្ថិតនៅក្នុងសមត្ថកិច្ច របស់ការិយាល័យនេះ។

### ២.៤.២ អាជ្ញាធរជាតិដើម្បីដោះស្រាយវិវាទដីធ្លី

អាជ្ញាធរជាតិដើម្បីដោះស្រាយវិវាទដីធ្លី បានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រដ/០២០៦/០៦៧ ចុះថ្ងៃទី ២៦ ខែ កម្ភៈ ឆ្នាំ ២០០៦។ ក្នុងរយពេលតែ ៦ ខែប៉ុណ្ណោះចាប់តាំងពីការបង្កើត អាជ្ញាធរនេះទទួលបានបណ្ដឹងដែលចុះបញ្ជីចំនួន ១១៦ ករណីពីប្រជាពលរដ្ឋ និងស្ថាប័នផ្សេងៗ ដែលក្នុងនោះ ៧៩ ករណីត្រូវបានបញ្ជូនទៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដី ដើម្បីពិនិត្យ។ នៅដំណាច់ឆ្នាំ ២០០៨ ចំនួនបណ្ដឹងបានកើនឡើងរហូតដល់ ១៥០០ ករណី។

ការងាររបស់អាជ្ញាធរ គឺដើម្បីពិនិត្យស្រាវជ្រាវបណ្ដឹងរបស់ប្រជាពលរដ្ឋ ឬស្ថាប័ន ហើយរៀបចំជាយោបល់បញ្ជូនទៅការិយាល័យឬក្រសួងដែលពាក់ព័ន្ធ។ យោងតាមអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃអាជ្ញាធរនេះ មាត្រា ៣ និង ៥ បានកំណត់ថា លេខាធិការដ្ឋាននៃអាជ្ញាធរនេះមានតួនាទី និងមុខងារដោះស្រាយ និងសម្របសម្រួលរាល់វិវាទដីធ្លី ហើយអគ្គលេខាធិការនៃអាជ្ញាធរនេះមានអំណាចចេញការណែនាំ ដើម្បីបញ្ឈប់នៅកន្លែងណាដែលមានវិវាទបន្ទាប់ពីទទួលបានបណ្ដឹង។

អាជ្ញាធរនេះមានអំណាចក្នុងការចុះស៊ើបអង្កេត និងធ្វើអធិការកិច្ច បន្ទាប់ពីទទួលបានបណ្ដឹង។ អនុក្រឹត្យនេះ ក៏បានលើកឡើងពីដំណើការនៃការចុះបញ្ជី និងការដោះស្រាយរឿងក្ដីផងដែរ។ ដំណើការនេះមាន:

១. ទទួល និងចុះបញ្ជីរឿងក្ដីតាមទីកន្លែងបណ្ដឹង

២. រៀបចំសំណុំរឿង

៣. បញ្ចូលក្នុងមូលដ្ឋានទិន្នន័យរឿងក្ដីដីធ្លី

៤. កោះអញ្ជើញភាគីដើម្បីបញ្ជាក់

៥. បញ្ជាក់ និងកំណត់អាទិភាពនៃរឿងក្ដី

៦. ប្រមូលភស្តុតាង

៧. សហការជាមួយស្ថាប័នរដ្ឋពាក់ព័ន្ធ ដើម្បីស្រាវជ្រាវដល់ទីកន្លែងវិវាទ

៨. រៀបចំរបាយការណ៍ជូនអគ្គលេខាធិការដើម្បីសម្រេច

៩. រៀបចំកំណត់បង្ហាញទាំងអង្គហេតុ និងអង្គច្បាប់ រួមនិងអនុសាសន៍ផ្សេងៗ ជូនថ្នាក់ដឹកនាំដើម្បីសម្រេច

១០. បញ្ជូនសេចក្តីសម្រេចទៅអាជ្ញាធរជាតិ ដើម្បីដោះស្រាយវិវាទដីធ្លី និងក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ដើម្បីអនុវត្ត

សំនួរចោទឡើងថា តើមតិយោបល់របស់អាជ្ញាធរជាតិនេះ ត្រូវបានអនុវត្តឬទេ ហើយថាតើរឿងក្តីនីមួយៗ ត្រូវបានដោយដោះស្រាយយ៉ាងដូចម្តេចនោះ មិនត្រូវបានបង្ហាញឱ្យបានច្បាស់នៅក្នុងរបាយការណ៍នេះទេ។ បន្ថែមពីនេះ ក៏មិនបានបង្ហាញថាតើ ប្រជាពលរដ្ឋពេញចិត្តនិងការដោះស្រាយនេះដែរទេ ហើយតើការដោះស្រាយនេះ មានរយៈពេលប៉ុណ្ណានោះ ក៏មិនបានបង្ហាញដែរ។

សេចក្តីដកស្រង់ពីរបាយការណ៍ឆ្នាំ ២០០៧ :

- បានចូលរួមដោះស្រាយបញ្ហារំលោភបំពានយកដីបរិស្ថាននៅស្រុកកំពង់សីលា ខេត្តកោះកុង ហើយប្រមូលដីមក ទុកជាសម្បត្តិរដ្ឋវិញបានចំនួន ៩០ ហិកតា ដោយសន្តិវិធី
- បានរៀបចំសេចក្តីជូនដំណឹងឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងបរិស្ថាន មានវិធានការ ផ្ទេរភារកិច្ច ដកមុខតំណែង និងបណ្តេញចេញពីក្របខ័ណ្ឌមន្រ្តីរាជការ ចំពោះប្រធានមន្ទីររៀបចំដែនដី នគរូបនីយ កម្មសំណង់ និងសុរិយោដី ខេត្តកោះកុង និងប្រធានមន្ទីរបរិស្ថានខេត្តកោះកុង ពាក់ព័ន្ធនឹងភាពមិនប្រក្រតី នៃការធ្វើប័ត្រសំគាល់កម្មសិទ្ធិកាន់កាប់អចលនវត្ថុ ក្នុងតំបន់ដែនជំរកសត្វព្រៃពាមក្រសាប ចិតក្នុងភូមិស្ទឹងវែង ឃុំ ស្ទឹងវែង ស្រុកស្មាចមានជ័យ ខេត្តកោះកុង
- បានចាត់វិធានការតាមផ្លូវច្បាប់ ចំពោះឧកញ៉ា តាន់ សេងហាក់ និង ឧកញ៉ា តែ ហាំង ដែលពាក់ព័ន្ធនឹងករណី រំលោភដីធ្លី និងកាប់ទន្រ្ទានដីព្រៃឈើដោយខុសច្បាប់ តែបច្ចុប្បន្នតុលាការកំពុងដំណើរការតាមនីតិវិធីច្បាប់
- បានរៀបចំលិខិតជូនដំណឹងដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលព្រៃឈើ ឱ្យមានវិធានការរដ្ឋបាលតឹងរឹងចំពោះមន្រ្តីចំនួន ១៥ រូប ព្រោះមន្រ្តីទាំងនោះបានរំលោភលើគោលការណ៍ច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីកិច្ច ការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសផ្គើននឹងបទបញ្ជាដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចនាយក រដ្ឋមន្រ្តី
- បានចុះដោះស្រាយករណីដីទំនាស់រវាងប្រជាពលរដ្ឋចំនួន ៩២ គ្រួសារជាមួយក្រុមហ៊ុន **ចំរើនជាតិ** និងលោក **សរ ស៊ីង** នៅភូមិ ៤ សង្កាត់អូរត្រេះ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ដោយតំរូវឱ្យសាលាក្រុង:
    - បង្កើតក្រុមការងារ ដើម្បីចុះស្រង់ស្ថិតិអ្នកដែលខ្វះដីពិតប្រាកដ ដែលបានរស់នៅលើដីទំនាស់
    - រៀបចំ និងបែងចែកដីសម្បទានសង្គមកិច្ច ចំពោះអ្នកដែលខ្វះដី និងគ្មានដី

○ សិក្សាស្រាវជ្រាវ រកមេក្លោងបំផុសបំផុលប្រជាពលរដ្ឋ ឱ្យទៅរស់នៅលើដីទំនាស់

- បានចុះដោះស្រាយករណី ប្រជាពលរដ្ឋ ៦០០គ្រួសារ ក្រុមហ៊ុន **សំ ផាន់ណារិទ្ធ** និងក្រុមហ៊ុន **សេង ហុងហេង** ដែលបានស្នើសុំមកវិញនូវផ្ទៃដីបង្កបង្កើនផល និងដីអភិវឌ្ឍន៍ ដែលខេត្តបានចេញដីការដកហូតកន្លងមកដោយបាន ផ្តល់អនុសាសន៍ឱ្យ :
- អនុគណៈកម្មាធិការខេត្ត ដើម្បីទប់ស្កាត់ លុបបំបាត់ និងបង្ក្រាបការកាប់រាន ដុតឈ្លូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើ ដើម្បីវាតយកដីធ្វើជាកម្មសិទ្ធិ ធ្វើការពិនិត្យជាក់ស្តែងចំពោះប្រជាពលរដ្ឋ ៦០០គ្រួសារ ដែលខេត្តបានចេញដីកាដកហូតដី
- ចំពោះសំណើរបស់ក្រុមហ៊ុន **សំ ផាន់ណារិទ្ធ** និងក្រុមហ៊ុន **សេង ហេងហុង** ដែលពាក់ព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី នឹងលើកយោបល់ស្នើសុំការសំរេចដ៏ខ្ពង់ខ្ពស់បំផុតពី សម្តេចនាយករដ្ឋ មន្ត្រី ។

## ២.៤.៣ ការិយាល័យ ដោះស្រាយវិវាទនៅក្រសួងពាណិជ្ជកម្ម

ការិយាល័យនេះ ស្ថិតនៅក្នុងនាយកដ្ឋាននីតិកម្មរបស់ក្រសួងពាណិជ្ជកម្ម ហើយដែលបានបង្កើតឡើងនៅឆ្នាំ ២០០៨។ នាយកដ្ឋាននេះ កំពុងតែធ្វើការរៀបចំរចនាសម្ព័ន្ធ ក្នុងពេលដែលក្រុមការងារអនុវត្តគម្រោងចុះជួប ។ ការិយាល័យនេះ បានរៀបចំឡើងតាមអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម។ គោលដៅរបស់ក្រសួងគឺ បង្កើតការិយាល័យទទួលពាក្យបណ្តឹងពីពាណិជ្ជករ ដែលមិនពេញចិត្តនិងសេចក្តីសម្រេចរបស់ក្រសួង ។

ការិយាល័យនេះ ស្ថិតនៅក្នុងក្រសួងពាណិជ្ជកម្ម តែមិនមានផ្លាកសញ្ញាណាមួយបង្ហាញពីកន្លែងដែលអាចស្វែងរកការិយាល័យនេះទេ ។ ការិយាល័យនេះ មានបុគ្គលិកចំនួន ២ នាក់ប្រធានការិយាល័យ និង អនុប្រធានការិយាល័យ ។ ការិយាល័យនេះមិនបានកំណត់ច្បាស់លាស់ពីថាតើបណ្តឹងត្រូវបានគេដោះស្រាយបែបណាទេ តែបទបញ្ញត្តិទាក់ទងនឹងការងារនេះ កំពុងតែរៀបចំ ។

មុនពេលដែលដែលមានការបង្កើតការិយាល័យនេះ បណ្តឹងមួយចំនួនបានបញ្ជូនដោយផ្ទាល់ទៅខុទ្ទកាល័យរដ្ឋមន្ត្រី ហើយបន្ទាប់មកបញ្ជូនទៅនាយកដ្ឋានជំនាញដើម្បីដោះស្រាយ ។ នាយកដ្ឋានអាចស្រាវជ្រាវរឿងក្តីនិងស្វែងរកដំណោះស្រាយដោយធ្វើការទាក់ទងជាមួយអ្នកប្តឹង ។ បើសិនជាមិនអាចដោះស្រាយបាន រឿងក្តីនឹងត្រូវរៀបចំជារបាយការណ៍អមដោយអនុសាសន៍ទៅរដ្ឋមន្ត្រីដើម្បីពិនិត្យ និងសម្រេច ។ មកទល់ពេលនេះ មិនមានស្ថិតិច្បាស់លាស់ពីចំនួនបណ្តឹងនោះទេ ប៉ុន្តែចំនួនបណ្តឹងដែលបាន់ស្មានមានប្រមាណ ១០ ករណីធំៗ និង ២០ រឿងក្តីតូចតាច ។

### ២.៤.៤ អគ្គាធិការដ្ឋានអធិការកិច្ច ក្រសួងមហាផ្ទៃ

អគ្គាធិការដ្ឋានអធិការកិច្ច ក្រសួងមហាផ្ទៃ ជាទូទៅ បានប្រតិបត្តិកិច្ចការរបស់ខ្លួន ជាការិយាល័យដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ អង្គភាពនេះ ធ្វើការស្រាវជ្រាវ និងធ្វើការជាមួយភាគីពាក់ព័ន្ធ ដើម្បីស្វែងរកដំណោះស្រាយដែលអាចទទួលយកបាន។ ការណីរឿងក្តីដីធ្លី ជារឿងក្តីគួរឱ្យកត់សម្គាល់ ហើយភាគរយនៃរឿងក្តីនេះកំពុងកើនឡើង និងស្ទះ នៅក្នុងអគ្គាធិការដ្ឋាននេះ។ អង្គភាពនេះ បានទទួលជំនួយពី USAID តាមរយៈវិទ្យាស្ថាន EWMI ដើម្បីកែលម្អសមត្ថភាពអគ្គាធិការដ្ឋានក្នុងការស្រាវជ្រាវ និងសម្រុះសម្រួលករណីដីធ្លីប្រកបដោយប្រសិទ្ធិភាព។ ក្រៅពីតួនាទីនេះ អគ្គាធិការដ្ឋាននៅមានទទួលបន្ទុកដោះស្រាយវិវាទផ្ទៃក្នុងនៅក្នុងក្រសួងផងដែរ។

### ២.៤.៥ អគ្គលេខាដ្ឋានអធិការកិច្ច ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

អគ្គលេខាដ្ឋានអធិការកិច្ច ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានតួនាទីពីរៈ ទទួលបន្ទុកធ្វើអធិកាកិច្ចផ្ទៃក្នុងប្រចាំឆ្នាំ និងជាការិយាល័យទទួលពាក្យបណ្តឹងផ្ទៃក្នុង។

នីតិវិធីនៃការដោះស្រាយបណ្តឹងផ្ទៃក្នុង គឺត្រូវបានបញ្ញត្តនៅក្នុងក្រសួង ដូចគ្នានឹងបទបញ្ញត្តនៃ ការដោះស្រាយបណ្តឹងផ្សេងទៀតរបស់ក្រសួងផ្សេងៗដែរ។ បណ្តឹងត្រូវបានរៀបចំដោយនាយកដ្ឋានអធិការកិច្ច ហើយបន្ទាប់មក ពីរការសម្រុះសម្រួលរវាងគូភាគីទាំងពីរ ហើយនាយកដ្ឋានរៀបចំកំណត់បង្ហាញអមដោយយោបល់ជំនាញ ដែលចុងក្រោយសម្រេចដោយរដ្ឋមន្ត្រី។ បើសិនជារឿងក្តីនោះ ជារឿងក្តីស្មុគស្មាញ ក្រុមការងារនឹងត្រូវរៀបចំឡើងដើម្បីស្រាវជ្រាវរឿងក្តី ហើយបើសិនជាចាំបាច់ក្រុមប្រឹក្សាវិន័យ ត្រូវរៀបចំប្រជុំដើម្បីសម្រេច។ នាយកដ្ឋាននេះ មិនមានរបាយការណ៍ ឬចំនួនបណ្តឹងច្បាស់លាស់ទេ។

### បណ្តឹងរបស់ពាណិជ្ជករ

មានលទ្ធភាពចំនួន ពីរ ចំពោះពាណិជ្ជករ ដែលមានបំណងប្តឹងពីសេចក្តីសម្រេចរបស់ក្រសួង ដូចជាការផ្តល់លិខិតអនុញ្ញាតជាដើម។ ពាណិជ្ជករអាចរៀបចំបណ្តឹងរបស់ខ្លួនទៅនាយកដ្ឋានជំនាញ ដែលទទួលបន្ទុកផ្តល់លិខិតអនុញ្ញាត្ត។ នាយកដ្ឋានត្រូវសិក្សារឿងក្តី លើកអនុសាសន៍ និងដាក់ជូនរដ្ឋមន្ត្រីដើម្បីពិនិត្យ និងសម្រេច។ បើសិនរឿងក្តីពាក់ព័ន្ធជាមួយក្រសួងច្រើនក្រុមការងារអន្តរក្រសួង នឹងរៀបចំឡើង ដើម្បីសិក្សាលើរឿងក្តីនេះ។

ជាងនេះទៀត ពាណិជ្ជករអាច រៀបចំបណ្តឹង តាមរយៈបណ្តាញទទួលពាក្យបណ្តឹងបន្ទាន់ លើបណ្តឹងទាក់ទងនឹងលិខិតអនុញ្ញាត្តពាណិជ្ជកម្ម (hotline complaint office)។ បណ្តាញទទួលពាក្យបណ្តឹងបន្ទាន់នេះ គឺមានតែមួយគត់នៅកម្ពុជា។ ពាណិជ្ជករអាចចុះបណ្តឹងរបស់ខ្លួនតាមរយៈបណ្តាញទូរស័ព្ទនេះ ដោយមិនចាំបាច់រងចាំពេលវេលាយូ ឬដំណើការរដ្ឋបាលទេ។ ពាណិជ្ជករអាចទូរស័ព្ទ ហើយផ្តល់ព័ត៌មានចាំបាច់មួយចំនួន ដូចជា

ឈ្មោះពាណិជ្ជកម្ម អ្នកទំនាក់ទំនងដែលមកប្តឹង និងមូលហេតុនៃបណ្តឹងជាដើម។ បើសិនជាមន្ត្រីដែលទទួលបន្ទុកនោះយល់ឃើញថា ត្រឹមត្រូវហើយ រឿងក្តីនេះ នឹងត្រូវបញ្ជូនទៅការិយាល័យជំនាញដើម្បីដោះស្រាយ។

បណ្តាញទទួលពាក្យបណ្តឹងបន្ទាន់ ចាប់ផ្តើមដំណើការប្រហែល ១ ឆ្នាំ មកហើយ។ មកទល់ពេលនេះមិនទាន់មានរបាយការណ៍ ពីចំនួននៃបណ្តឹងនីតិវិធីនៃដំណើរឿងក្តី និងភាពពេញចិត្តរបស់អ្នកប្តឹងនៅឡើយទេ។

## ២.៤.៦ មជ្ឈមណ្ឌលសេវាកម្មយុត្តិធម៌ ក្រសួងយុត្តិធម៌

នៅខែកក្កដា ឆ្នាំ២០០៧ មជ្ឈមណ្ឌលសេវាកម្មយុត្តិធមិ បានបើកដំណើការនៅខេត្តកំពង់ស្ពឺ និងកំពង់ឆ្នាំង។ បច្ចុប្បន្ននេះ មានមជ្ឈមណ្ឌលយុត្តិធមិចំនួន ២០ នៅខេត្តចំនួន ៦ កំពុងដំណើការ (កំពង់ស្ពឺ កំពង់ឆ្នាំង បាត់ដំបង សៀមរាប មណ្ឌលគីរី និងរតនគីរី) ហើយមជ្ឈមណ្ឌលយុត្តិធមិចំនួន ១០ ផ្សេងទៀតគ្រោងនឹងពង្រីកបន្ថែមនៅក្នុងឆ្នាំ២០០៩ នេះ (៤ស្រុក នៅខេត្តព្រៃវែង ២ស្រុកនៅខេត្តកំពត និង ៤ ស្រុកនៅរាជធានីភ្នំពេញ)។

គោលបំណងនៃមជ្ឈមណ្ឌលសេវាកម្មយុត្តិធមិ ដែលគាំទ្រដោយ UNDP គឺដើម្បីផ្តល់ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេស ដល់ស្ថាប័នដោះស្រាយវិវាទថ្នាក់មូលដ្ឋាន លើជំនាញសម្រុះសម្រួល និងចំណេះដឹងជាមូលដ្ឋានផ្នែកច្បាប់ ធ្វើការវាយតម្លៃពីតម្រូវការព័ត៌មានច្បាប់នៅថ្នាក់មូលដ្ឋាន និងផ្សព្វផ្សាយព័ត៌មានច្បាប់ដល់មន្ត្រីមូលដ្ឋាន និងសាធារណៈជនតាមស្រុកនីមួយៗ។

ជាងនេះទៀតមន្ត្រីក្នុងមជ្ឈមណ្ឌលសេវាកម្មយុត្តិធមិ អាចធ្វើការសម្រុះសម្រួល និងផ្សះផ្សាវិវាទស៊ីវិល បើសិនជាភាគីជំលោះយល់ព្រម ហើយមន្ត្រីនោះអាចផ្តល់សេវាកម្មអាជ្ញាកណ្តាលសម្រាប់ភាគីជំលោះ ដែលមានរឿងក្តីមិនអាច ឬមិនចង់សម្រុះសម្រួលនៅថ្នាក់មូលដ្ឋាន។

មជ្ឈមណ្ឌលសេវាកម្មយុត្តិធមិដែលស្ថិតនៅថ្នាក់ស្រុកមានបុគ្គលិក ២ រូប មួយជាប្រធានដែល តែងតាំងដោយក្រសួងយុត្តិធមិ ០១រូប និងជំនួយការ ០១រូប។ បន្ថែមពីនេះ មជ្ឈមណ្ឌលសេវាកម្មយុត្តិធមិនីមួយៗមានក្រុមប្រឹក្សាមួយ ដែលទទួលបន្ទុកសម្រុះសម្រួលវិវាទ មានន័យថាស្វែងរកដំណោះស្រាយដែលអាចទទួលយកបានសម្រាប់ភាគីជំលោះទាំងពីរ។ ក្រុមប្រឹក្សាមានសមាសភាពមកពីមេឃុំ តំណាងនគរបាលមួយរូប តំណាងស្ត្រីមួយរូប និងប្រជាពលរដ្ឋចំនួន ៤ រូប ដែលជ្រើសរើសពីអ្នកភូមិ។

ដំណើការនៃរឿងក្តី: រឿងក្តីរបស់ប្រជាពលរដ្ឋត្រូវបានពិនិត្យ ហើយតំណាងមជ្ឈមណ្ឌលយុត្តិធមិជួបប្រជុំជាមួយភាគីចុងចោទ ហើយកំណត់ថាតើ ភាគីទាំងពីររៀបចំដោះស្រាយរឿងក្តីនៅក្រុមប្រឹក្សាឬទេ បើភាគីទាំងពីរយល់ព្រម រឿងក្តីនឹងចាប់ផ្តើមនៅក្រុមប្រឹក្សា ហើយព្យាយាមដើម្បីសម្រេចនូវដំណោះស្រាយរួមមួយ។ ផ្អែកលើបទពិសោធន៍នៅថ្នាក់ស្រុក ប្រជាពលរដ្ឋជាទូទៅយល់ស្របតាមដំណើការនេះ។

រឿងក្តីដែលកើតមានឡើងនៅមជ្ឈមណ្ឌលយុត្តិធម៌មានៈ ទីមួយ និងច្រើនជាងគេ គឺវិវាទដីធ្លី ទីពីរ គឺអំពើហឹង្សាក្នុងគ្រួសារ និងទីបី គឺទាក់ទងនឹងកិច្ចសន្យា ភាគរយនៃការដោះស្រាយដែលទទួលបានជោគជ័យមានកំរិតខ្ពស់ ដែលជាមធ្យមគឺ ៦០ ភាគរយ ។ ស្ថិតិត្រីមាសទីមួយនៃឆ្នាំ ២០០៨ មានដូចខាងក្រោមៈ

**ឧទាហរណ៍ ស្រុកភ្នំស្រួច**

| | | |
|---|---|---|
| រឿងក្តីនៅសល់ពីឆ្នាំ ២០០៧ | ចំនួន | ១០៣ |
| រឿងក្តីដែលទទួលបាននៅត្រីមាសទីមួយ | ចំនួន | ២៨ |
| រឿងក្តីដោះស្រាយបានជោគជ័យ | ចំនួន | ៨៤ |
| រឿងក្តីដែលដោះស្រាយមិនជោគជ័យ | ចំនួន | ២៧ |
| រឿងក្តីដែលសុំដកវិញ | ចំនួន | 0 |
| រឿងក្តីដែលសល់សម្រាប់អនុវត្តត្រីមាសក្រោយ | ចំនួន | ១០ |

**ឧទាហរណ៍ ស្រុកគងពិសី**

| | | |
|---|---|---|
| រឿងក្តីសល់ពីឆ្នាំ ២០០៧ | ចំនួន | ៣៨ |
| រឿងក្តីដែលទទួលបានក្នុងត្រីមាសទីមួយ | ចំនួន | ៥៨ |
| រឿងក្តីដោះស្រាយបានជោគជ័យ | ចំនួន | ៦០ |
| រឿងក្តីដោះស្រាយមិនបានជោគជ័យ | ចំនួ ន | 0 |
| រឿងក្តីសុំដកវិញ | ចំនួន | ១ |
| រឿងក្តីសល់សម្រាប់អនុវត្តត្រីមាសក្រោយ | ចំនួន | ៣៦ |

**ស្រុកកំពង់លែង**

| | | |
|---|---|---|
| រឿងក្តីសល់ពិឆ្នាំ ២០០៧ | ចំនួន | ១៤ |
| រឿងក្តីដែលទទួលបានក្នុងត្រីមាសទីមួយ | ចំនួន | ៦ |
| រឿងក្តីដោះស្រាយបានជោគជ័យ | ចំនួន | ១៣ |

រឿងក្តីដោះស្រាយមិនបានជោគជ័យ ចំនួន ០

រឿងក្តីសុំដកវិញ ចំនួន ០

រឿងក្តីសល់សម្រាប់អនុវត្តត្រីមាសក្រោយ ចំនួន ៧

## ២.៤.៧ ក្រុមការងារសម្រាប់រៀបចំសេចក្តីព្រាងច្បាប់នគរបាល សម្រាប់នគរបាលជាតិកម្ពុជា

សេចក្តីព្រាងច្បាប់នគរបាលមួយ បាន និងកំពុងរៀបចំឡើងនៅអគ្គលេខាធិការដ្ឋាននគរបាលជាតិ ចាប់ពីខែមិថុនា ឆ្នាំ ២០០៨ មក ដែលនឹងពិនិត្យមើលឡើងវិញនូវរចនាសម្ព័ន្ធ និងការទទួលខុសត្រូវរបស់នគរបាលជាតិកម្ពុជា។ ជាងនេះទៀត ក្រមសីលធម៌ និងវិន័យលើការការពារ ក៏នឹងត្រូវរៀបចំជាមួយគ្នានេះដែរ។

ភ្ជាប់ជាមួយនឹងការរៀបចំសេចក្តីព្រាងច្បាប់នេះ ដំណើការមួយត្រូវបានរៀបចំដើម្បីបញ្ចូលនូវយន្តការដែលផ្តល់លទ្ធភាព ឱ្យប្រជាពលរដ្ឋប្តឹងពីនគរបាលក្នុងករណីការបំពេញការងារមិនសមស្រប។ ទាំងនេះនឹងធានាថាសាធារណៈជនទាំងអស់ អាចជឿទុកចិត្តចំពោះភាពស្មោះត្រង់ និងភាពសុចរិត របស់នគរបាលជាតិបាន។

នីតិវិធី និងអ្វីដែលការិយាល័យនេះ នឹងទទួលបន្ទុក សម្រាប់ការប្តឹងបែបនេះ និងរៀបចំពិភាក្សានៅក្នុង ៖ ក្នុងអំឡុងឆ្នាំ ២០០៩ នេះ។ ប៉ុន្តែ ការរៀបចំអំប៊ុដ្សម៉ានសម្រាប់នគរបាល អាចមានលទ្ធភាព បង្កើតបាន នេះបើតាមការអះអាងរបស់ជំនាញការអន្តរជាតិដែលទទួលបន្ទុកការងារនេះ។

## ២.៤.៨ ក្រសួងទំនាក់ទំនងសភា ព្រឹទ្ធសភា និងអធិការកិច្ច

ក្រសួងបានដើរតួនាទីយ៉ាងសំខាន់ ជួយរដ្ឋាភិបាលរៀបចំអនុវត្តធ្វើអធិការកិច្ច លើការបំពេញការងាររបស់ក្រសួង និងភ្នាក់ងាររដ្ឋាភិបាល ដើម្បធានាបាននូវការទទួលខុសត្រូវ និងតម្លាភាពសម្រាប់រាជរដ្ឋាភិបាលក៏ដូចជាប្រជាពលរដ្ឋ។ យោងតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រពឹត្តទៅរបស់ក្រសួង រាជរដ្ឋាភិបាលបានផ្តល់អំណាចពេញលេញដល់អគ្គនាយកដ្ឋានអធិការកិច្ច ដើម្បីធ្វើអធិការកិច្ច និងដោះស្រាយដោយឈរលើការសម្រុះសម្រួលទំនាស់ប្រឆាំងនឹងរដ្ឋបាល។

ទាក់ទិននឹងការដោះស្រាយទំនាស់ប្រឆាំងនឹងរដ្ឋបាល នាយកដ្ឋានទទួលពាក្យបណ្តឹងនឹងស៊ើបអង្កេតទទួលខុសត្រូវទទួលពាក្យបណ្តឹង ពីគ្រប់មជ្ឈដ្ឋានទាក់ទិននឹងបណ្តឹងចំពោះរដ្ឋបាល ហើយធ្វើការស៊ើបអង្កេតនិងដោះស្រាយដោយយន្តការសម្រុះសម្រួល។ រឿងក្តីភាគច្រើន ក្រសួងមិនមានអំណាចដើម្បីសម្រេចទេ តែក្រសួងបានរៀបចំសុំណុំបែបបទជាមួយនិងអនុសាសន៍ទៅនាយករដ្ឋមន្ត្រីដើម្បីសម្រេច។

នីតិវិធីនៃការដោះស្រាយទំនាស់ ជាទូទៅដូចជាដំនើការនៃការដោះស្រាយទំនាស់របស់ក្រសួងស្ថាប័នផ្សេង

ទៀតដែរ។ ពេលដែលទទួលបានរឿងក្តី នាយកដ្ឋានបានរៀបចំពិនិត្យ និងកំណត់ថាតើរឿងក្តីនេះស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួនឬទេ ហើយបើមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន ក្រសួងនឹងរៀបចំបញ្ជូនទៅក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយ និងស្នើសុំរបាយការណ៍។ រឿងក្តីភាគច្រើន ដែលក្រសួងបានទទួល គឺជារឿងក្តីដីធ្លី។ មកទល់ពេលនេះមិនទាន់មានស្ថិតិច្បាស់លាស់ណាមួយរបស់ក្រសួងទាក់ទិននឹងរឿងក្តីនៅឡើយទេ។

ទាក់ទិននឹងការធ្វើអធិការកិច្ច នាយកដ្ឋានអធិការកិច្ច ទទួលខុសត្រូវរៀបចំផែនការអធិការកិច្ចប្រចាំឆ្នាំ ដើម្បីអនុវត្តការធ្វើអធិការកិច្ចលើបណ្តាក្រសួងស្ថាប័នរដ្ឋាភិបាលផ្សេងៗ។ បច្ចុប្បន្ននេះ ការងារអធិការកិច្ចក្រសួងមាននីតិវិធី និងផែនការត្រឹមត្រូវ និងច្បាស់លាស់។ នាយកដ្ឋាន បានចុះធ្វើអធិកាកិច្ចដោយផ្ទាល់ ដើម្បីពិនិត្យមើលភាពមិនត្រឹមត្រូវនៃការបំពេញការងាររបស់ក្រសួង ស្ថាប័នរដ្ឋាភិបាល ជាពិសេសផ្តោតលើការចំណាយរបស់ក្រសួងស្ថាប័ននីមួយៗ។

## ២.៤.៩ អង្គភាពប្រឆាំងអំពើពុករលួយ

អង្គភាពប្រឆាំងអំពើពុករលួយ បានបង្កើតឡើងនៅឆ្នាំ ២០០៦។ វាជាអ្នកស្នងអង្គភាពប្រឆាំងអពើពុករលួយ ដែលបានបង្កើតឡើងនៅឆាំ ១៩៩៩ ហើយដែលមិនមានអំណាចគ្រប់គ្រាន់។ អង្គភាពប្រឆាំងអំពើពុករលួយថ្មី បានបង្កើតឡើង ជាមួយនឹងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខ្លួន លេខ ៨៤ អនក្រ ចុះថ្ងៃទី ២២ សីហា ២០០៦ ដែលមានតួនាទីចម្បង គឺ ការបង្ការទប់ស្កាត់ជាមុន ការពង្រឹងការអនុវត្តច្បាប់ និងការគាំទ្រពីមហាជនក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

អង្គភាពនេះ ស្ថិតនៅក្រៅទីប្រជុំជនក្នុងក្រុងភ្នំពេញ។ អាគារមានដាក់ផ្លាកសញ្ញាច្បាស់លាស់ ហើយដែលមានផ្លូវចូលធំទូលាយ ជាមួយនឹងប្រអប់ពិណស ដែលសំបុត្របណ្តឹងសម្រាប់អង្គភាពនេះ អាចត្រូវបានគេដាក់បានដោយសេរី។

ការងាររបស់អង្គភាពនេះ ផ្តោតលើសកម្មភាពបីជាសំខាន់: គឺ ការបង្ការទប់ស្កាត់ជាមុន ការពង្រឹងការអនុវត្តច្បាប់ និងការគាំទ្រពីមហាជនក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ សកម្មភាពដែលមានប្រជាប្រិយភាពចាប់តាំងពីការបង្កើត គឺយុទ្ធនាការបុណ្យអុំទូក និងយុទ្ធនាការហោននីកេន។ យុទ្ធនាការបុណ្យអុំទូក គឺការប្រតិបត្តិការលើការនាំចូលឡានចង្កូតស្តាំខុសច្បាប់ពីថៃ ដែលមានទំនាក់ទំនងនិងអំបើពុករលួយចំពោះ មន្ត្រីរដ្ឋាភិបាល។ រឿងក្តីហោននីកេន ក៏ដូចគ្នានេះដែរ។ រឿងក្តីទាំងពីរបានបញ្ជូនដល់តុលាការ ដើម្បីដោះស្រាយ។

ក្នុងករណីពេលដែលតទួលបានរឿងក្តី អង្គភាពបានរៀបចំដំណើការដូចជា ទីមួយរៀបចំពិនិត្យថាតើជាសមត្ថកិច្ចរបស់ខ្លួនឬទេ បើសិនជាសមត្ថកិច្ច អង្គភាពនឹងរៀបចំពិនិត្យ និងកំណត់ថាតើភស្តុតាងនេះមាន

លក្ខណៈគ្រាន់គ្រាន់ហើយឬនៅ។ បើសិនភស្តុតាងគ្រប់គ្រាន់ហើយ អង្គភាពនិងទទួលសិទ្ធិពីប្រធានអង្គភាព ធ្វើការស៊ើបអង្កេត។ ពេលដែលការស៊ើបអង្កេតបានបញ្ចប់ របាយការណ៍ត្រូវបញ្ជូនទៅនាយកដ្ឋមន្ត្រី ឬ ឧបនាយករដ្ឋមន្ត្រី។ នាយកដ្ឋមន្ត្រី ឬឧបនាយករដ្ឋមន្ត្រី ធ្វើសេចក្តីសម្រេច ជាមួយនឹងវិធានការដើម្បីអនុវត្ត។

អង្គភាពនេះ មានមេធាវីចំនួន ១៥ រូប បំរើការងារ ដែលទទួលបន្ទុកស៊ើបអង្កេតអំពើពុករលួយ។ អង្គភាពនេះ បានរៀបចំការផ្សព្វផ្សាយមួយចំនួនតាមរយៈទូរទស្សន៍ ដើម្បីបង្ហាញពីអង្គភាពដល់ប្រជាពលរដ្ឋ។ មិនទាន់មានស្ថិតិពី ចំនួនរឿងក្តីដែលកំពុងស៊ើបអង្កេត និងបានដោះស្រាយ ឱ្យបានច្បាស់លាស់នៅឡើយទេ ហើយក៏មិនមានចំនួននៃការប្តឹងតាមរយៈប្រអប់សំបុត្រស ប៉ុន្មាននៅឡើយ ត្រូវបានចេញផ្សាយនោះទេ។

## ២.៥ កិច្ចសម្ភាសជាមួយអង្គការក្រៅរដ្ឋាភិបាល

### ២.៥.១ ការិយាល័យនៃឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

តាមរយៈការិយាល័យនេះ មានករណីនៃការស៊ើបសួរ និងបណ្តឹងជាច្រើនកំពុងកើតមានឡើង។ ប្រជាពលរដ្ឋកម្ពុជា ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាល បានស្នើសុំការិយាល័យនេះ ដើម្បីជួយ និងណែនាំ។ តាមរយៈការិយាល័យនេះ ចំនួននៃបណ្តឹងទាក់ទងនឹងសិទ្ធិមនុស្ស បានកើនឡើងជាលំដាប់។ បណ្តឹងដែលស្ថិតនៅចំណាត់ថ្នាក់ទីមួយ គឺ បណ្តឹងទាក់ទងនឹងវិវាទដីធ្លី។ ការិយាល័យនេះ បានទទួលបណ្តឹងទាក់ទងនឹងអំពើហឹង្សាក្នុងគ្រួសារ ស្ថានភាពពន្ធនាគារ ពីប្រជាពលរដ្ឋដែលទទួលរងនូវការរំលោភសិទ្ធិមនុស្ស (សេរីភាពបញ្ចេញមតិ សេរីភាពធ្វើបាតុកម្ម..)។

ការិយាល័យនេះ មិនមែនជាការិយាល័យទទួលពាក្យបណ្តឹង ដែលផ្តល់យោបល់ និងតំណាងប្រជាពលរដ្ឋទេ។ ការិយាល័យនេះ គ្រាន់តែផ្តល់ព័ត៌មានពីអង្គការក្រៅរដ្ឋាភិបាល និងការិយាល័យរដ្ឋាភិបាលណាដែលអាចជួយដោះស្រាយបញ្ហាដែលជាការបារម្ភរបស់ប្រជាពលរដ្ឋ។ ទោះបីជាយ៉ាងណាក៏ដោយ តួនាទីរបស់ការិយាល័យនេះ ទាក់ទងនឹងរដ្ឋបាល និងភ្នាក់ងាររាជរដ្ឋាភិបាល គឺដើម្បីលើកដំកើងសន្តិសុខផ្លូវច្បាប់សម្រាប់ប្រជាពលរដ្ឋ និងជួយកាត់បន្ថយការរំលោភសិទ្ធិមនុស្ស។ ការិយាល័យនេះ មានគោលបំណងធ្វើការដោយជឿទុកចិត្តគ្នាជាមួយរដ្ឋបាលកម្ពុជា ហើយក៏ធ្វើការគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលផងដែរដើម្បី លើកឡើងនូវបញ្ហាដែលបានលើកឡើងខាងលើ។ ក្នុងពេលកិច្ចសម្ភាសនេះ តំណាងការិយាល័យនេះ បានលើកឡើងម្តងហើយម្តងទៀតថា ការជឿទុកចិត្តលើការិយាល័យទទួលពាក្យបណ្តឹងរបស់មន្ត្រីរដ្ឋាភិបាល គឺនៅក៏រិតទាប។ តាមរយៈបទពិសោធន៍របស់ខ្លួន ប្រជាពលរដ្ឋជាទូទៅហាក់ដូចជាទុកចិត្តអង្គការក្រៅរដ្ឋាភិបាល ឬស្ថាប័នឯករាជ្យដើម្បីដោះស្រាយ បណ្តឹងរបស់ខ្លួនច្រើនជាង។

### ២.៥.២ សមាគមអភិវឌ្ឍន៍ និងសិទ្ធិមនុស្សកម្ពុជា អាដហុក

ជាមធ្យម ប្រជាពលរដ្ឋប្រមាណ ៣០០ ក្នុងប្រទេសកម្ពុជា ស្វែងរកការគាំទ្រពីអង្គការនេះ ជារៀងរាល់ខែ។ បញ្ហាដែលស្ថិតនៅលំដាប់ខ្ពស់ជាងគេ គឺ អំពើហឹង្សាក្នុងគ្រួសារ ដែលមានប្រហែល ១០០ ករណីក្នុងមួយខែ ការរំលោភសិទ្ធិមនុស្ស ចំនួន ៤០-៥០ ករណីក្នុងមួយខែ វិវាទដីធ្លី ៣០-៤០ ករណីក្នុងមួយខែ។ តាមរយៈអង្គការនេះ ចំនួននេះ មានការកើនឡើងជានិច្ច។

អង្គការនេះ ក៏ដូចជាអង្គកាក្រៅរដ្ឋាភិបាលផ្សេងទៀតដែរ មិនមានអាណត្តិ ដើម្បីដោះស្រាយបណ្តឹងដែលបានទទួលជាមួយមន្ត្រីរដ្ឋាភិបាលទេ។ អង្គការនេះ អាចផ្តល់យោបល់ ដល់ភាគីរងគ្រោះ។ វិវាទជាច្រើនដូចជា ដីធ្លីជាមួយអាជ្ញាធរមូលដ្ឋាន អង្គការនេះ បានជួយប្រជាពលរដ្ឋតាមរយៈការផ្តល់យោបល់ផ្នែកច្បាប់ រៀបចំផ្សព្វផ្សាយ និងចាត់វិធានការផ្សេងៗ។

## ២.៦ សេចក្តីសង្ខេប

ការសិក្សាបឋម ស្តីពីការិយាល័យទទួលពាក្យបណ្តឹង នៅកម្ពុជានេះ មិនទាន់បានពេញលេញនៅឡើយទេ។ នៅមានស្ថាប័នជាច្រើនផ្សេងទៀត ដូចជា ការិយាល័យទទួលពាក្យបណ្តឹងរបស់រដ្ឋសភាដែលមិនទាន់បានជួបសម្ភាស។ ទាំងនេះ គឺដោយសារតែ មានការមមាញឹក្នុងការរៀបចំរដ្ឋាភិបាលថ្មីនៅខែកញ្ញា ឆ្នាំ ២០០៨ បន្ទាប់ពីការបោះឆ្នោត ហើយការទទួលបន្ទុករបស់ស្ថាប័នផ្សេងៗមានការផ្លាស់ប្តូរ ជាមួយគ្នានេះ ភាគីដែលទទួលបន្ទុកមិនទាន់យល់ច្បាស់ពីការទទួលខុសត្រូវរបស់ខ្លួននៅក្នុងតំណែងថ្មីនៅឡើយ។

ភាគច្រើននៃការិយាល័យទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ ទោះបីជានៅក្នុងក្រសួង ឬនៅការិយាល័យប្រជាពលរដ្ឋនៅស្រុកបាត់ដំបង និងសៀមរាបក៏ដោយ ជាការិយាល័យថ្មីនៅឡើយ។ ការិយាល័យទាំងនេះបានត្រូវបង្កើតឡើង ក្នុងរយៈពេល ពីរបីឆ្នាំមកនេះ។ ទាំងនេះ បង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឱ្យរដ្ឋបាល កាន់តែមានតម្លាភាព និងផ្តល់ឱ្យប្រជាពលរដ្ឋនូវលទ្ធភាពពិនិត្យមើលសេចក្តីសម្រេចដែលធ្វើឡើងដោយរដ្ឋបាល សាធារណៈ។

មកដល់ពេលនេះ មានការិយាល័យ និងអង្គភាព ចំនួន ៥ ប្រភេទ ដែលទទួលបន្ទុកទទួលពាក្យបណ្តឹង និងដោះស្រាយបណ្តឹងនៅក្នុងក្រសួង ស្ថាប័នដែលទទួលបន្ទុកប្រហាក់ប្រហែលគ្នា:

១. សវនកម្មផ្ទៃក្នុងរបស់ក្រសួងស្ថាប័ន

២. អធិការកិច្ចផ្ទៃក្នុងរបស់ក្រសួងស្ថាប័ន

៣. ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

៤. អាជ្ញធរសវនកម្មជាតិ

៥. អង្គភាពប្រឆាំងអំពើពុករលួយ

ការិយាល័យទទួលពាក្យបណ្តឹងភាគច្រើននៅក្នុងក្រសួង ទទួលបន្ទុកទាំងបណ្តឹងផ្ទៃក្នុង ទាំងបណ្តឹងមកពីក្រៅ។ ភាគច្រើននៃការិយាល័យទទួលពាក្យបណ្តឹងស្ថិតនៅក្នុងក្រសួងខ្លួនឯង ហើយដែលជាទូទៅមានការពិបាកក្នុងកាស្វែងរក ដោយសារតែគ្មានផ្លាកសញ្ញាបង្ហាញច្បាស់លាស់។ ប្រជាពលរដ្ឋដែល ចង់ស្វែងរកការិយាល័យនេះ ត្រូវតែសួរមន្ត្រីដែលនៅក្នុងក្រសួងនេះ ដើម្បីរកការិយាល័យនេះលើកលែងតែអាជ្ញាធរជាតិ ដើម្បីដោះស្រាយទំនាស់ដីធី ដែលស្ថិតនៅកន្លែងមួយដោយឡែក។

ដំណើការថាតើបណ្តឹងពីប្រជាពលរដ្ឋត្រូវបានដោះស្រាយបែបណានោះ គឺមានលក្ខណៈឯកភាពដូចគ្នាជាទូទៅ។ បណ្តឹងត្រូវបានចុះបញ្ជី ហើយត្រូវបានពិនិត្យ ឬស្នើសុំសេចក្តីសម្រេចពីនាយកដ្ឋានជំនាញ។ បើសិនបណ្តឹង ត្រូវបានចាត់ទុកថាត្រឹមត្រូវហើយ ការស្នើសុំនៃការព្រមព្រៀង នឹងត្រូវបានរៀបចំ។ បើសិនជាភាគីទាំងពីរយល់ព្រម រឿងក្តីនឹងបញ្ចប់ ប៉ុន្តែបើមិនយល់ព្រម រឿងក្តីនេះ នឹងត្រូវរៀបចំជាកំណត់បង្ហាញរួមនិងអនុសាសន៍ទៅរដ្ឋមន្ត្រី។

មានការិយាល័យទទួលពាក្យបណ្តឹងតិចតួចទេដែលរៀបចំការងារផ្សព្វផ្សាយ។ ដូច្នេះហើយ ត្រូវបានគេគិតថា ការកើតឡើងនូវការិយាល័យនេះ មិនត្រូវបានស្គាល់ពីប្រជាពលរដ្ឋទេ។

មានស្ថិតិតិចតួចប៉ុណ្ណោះដែលបង្ហាញពីការងាររបស់ការិយាល័យទទួលពាក្យបណ្តឹង។ ស្ថិតិដូចជាពី ចំនួនពាក្យបណ្តឹងដែលបានចុះបញ្ជីប្រចាំឆ្នាំ ពីអត្ថន័យនៃបណ្តឹង ឬក៏ថាតើពាក្យបណ្តឹងទាំងនោះ ត្រូវបានគេដោះស្រាយរបៀបណា មិនទាន់មាន និងមិនមាន ឬក៏គ្មានការផ្សព្វផ្សាយនៅឡើយ។ មកដល់ពេលនេះ សិក្សាស្ទង់មតិអំពីការអង្កេតពីការពេញចិត្តរបស់អតិថិជន ក៏មិនទាន់មាននៅឡើយទេដែរ។

ការត្រួសត្រាយថ្មីមួយ ត្រូវបានរៀបចំធ្វើឡើងជាមួយនឹងយន្តការបណ្តឹងតាមបណ្តាញបន្ទាន់ (hotline) (ការិយាល័យទាន់ហេតុការណ៍) របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលបានកែលម្អសេវាកម្មសម្រាប់ពាណិជ្ជកម្ម ជាពិសេសសហគ្រិនធុនតូច និងមធ្យម។ គេអាចប្រើប្រាស់សេវាកម្មនេះ ដើម្បីពិនិត្យពីសេចក្តីសម្រេចលិខិតអនុញ្ញាត្ត យ៉ាងលឿន និងដោយមិនមានភាពសាំញ៉ាំ។ តែទោះបីជាយ៉ាងណាក៏ដោយ ស្ថិតិនៃបណ្តឹងក៏មិនទាន់មាន ដូច្នេះហើយ មិនទាន់មានមតិយោបល់ណាដែលនិយាយពីការទទួលយក ឬការពេញចិត្តរបស់អតិថិជនដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការបន្តអភិវឌ្ឍនូវបទបង្ហាញឱ្យបានទៅតាមគម្រោងនេះនឹងផ្តល់នូវសូចនាករគួរឱ្យចាប់អារម្មណ៍ សម្រាប់ការអភិវឌ្ឍន៍នាពេលអនាគត នៃការិយាល័យទទួលពាក្យបណ្តឹងនេះ។

ការិយាល័យប្រជាពលរដ្ឋនៅបាត់ដំបង បានកំពុងតែបើកនូវលទ្ធភាពឱ្យប្រជាពលរដ្ឋប្រឈម និងសេចក្តីសម្រេចដោយរដ្ឋបាល និងការពារប្រឆាំងនឹងសេចក្តីសម្រេចដែលមិនត្រឹមត្រូវ។ ទោះបីជាយ៉ាងណាក៏ដោយការអនុវត្តប្រព័ន្ធអំប៊ុដ្ស្មាន់ នៅស្រុកបាត់ដំបង បានជួបប្រទេះបញ្ហាជាច្រើន។ មូលហេតុផ្សេងៗនៃបញ្ហាទាំងនេះមានៈ

- ប្រជាពលរដ្ឋជាច្រើនមិនទាន់យល់ពីការអត្ថិភាពអំប៊ុដ្ស្មាន់នេះទេ ទោះបីជាមានប័ណ្ណព័ត៌មាន ត្រូវបានគេចែកផ្សាយ កម្មវិធីជជែកតាមវិទ្យុត្រូវបានរៀបចំ ក៏ដោយ ក៏ប្រជាពលរដ្ឋមួយចំនួនដែល បានសួរនាំបានបង្ហាញថា ក៏រិតនៃការផ្សព្វផ្សាយ នៅទាប។ ប្រជាពលរដ្ឋតិចជាង ៥ ភាគរយបានដឹងពីការិយាល័យនេះ[១]។

- ប្រជាពលរដ្ឋមិនមានភាពក្លាហាន ដើម្បីប្តឹងពីរដ្ឋបាលសាធារណៈ ដោយសារតែមិនអាចចូលទៅប្តឹងដោយគ្មានការឃ្លាំមើលបាន។ លទ្ធភាពដែលទុកឱ្យប្រជាពលរដ្ឋមិនបានសួរនាំការិយាល័យនេះ មិនត្រូវផាត់ចោលនោះឡើយ។

- ប្រជាពលរដ្ឋមិនជឿលើការិយាល័យនេះ ថាអាចជួយខ្លួនបានក្នុងទំនាស់ជាមួយរដ្ឋបាល។

- ពាក្យអំប៊ុដ្ស្មាន់ មិនទាន់មានក្នុងភាសាខ្មែរនៅឡើយ ដូចច្នេះហើយ បានជាគេឱ្យឈ្មោះការិយាល័យនៅបាត់ដំបងនេះ ថា ជាការិយាល័យប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋជាច្រើនយល់ថា ឈ្មោះការិយាល័យនេះមានផលអវិជ្ជមាន លើការផ្សព្វផ្សាយសាធារណៈនៃការិយាល័យប្រជាពលរដ្ឋ។ ដើម្បីឱ្យមានភាពច្បាស់លាស់ ពីតួនាទីរបស់ការិយាល័យនេះ ឈ្មោះដែលអាចជា "ការិយាល័យទទួលពាក្យបណ្តឹង" ឬ "ការិយាល័យទំនាក់ទំនងប្រជាពលរដ្ឋ" ឬ "ការិយាល័យជួយប្រជាពលរដ្ឋ" ត្រូវបានលើកឡើង ដោយប្រជាពលរដ្ឋមួយចំនួន។

ការវាយតម្លៃផ្ទៃក្នុងមួយដែលធ្វើឡើងដោយក្រសួងមហាផ្ទៃ បានសន្និដ្ឋានថា អំប៊ុដ្ស្មាន់នៅតែជាការៀបចំថ្មីមួយដែលមាន លក្ខណៈសកល។ អំប៊ុដ្ស្មាន់ បានបង្កើតយន្តការមួយដែលពង្រឹងតម្លាភាព ដើម្បីដោះស្រាយបញ្ហាពុករលួយ និងដើម្បីបង្កើតភាពទុកចិត្តរបស់ប្រជាពលរដ្ឋក្នុងរដ្ឋបាលស្រុក។ ជាងនេះទៀត កាបង្ហាញខ្លួនរបស់ការិយាល័យ នេះ បានដើរតួនាទីដោយផ្ទាល់ ជាកត្តាចម្បងក្នុងការធានាប្រសិទ្ធភាព និងតម្លាភាព ក្នុងការអនុវត្តច្រកចេញ ចូលតែមួយ[២]។ ក្រសួងមហាផ្ទៃផ្តល់អនុសាសន៍ថា ៈ

- ទីកន្លែងការិយាល័យនេះ គប្បី ស្ថិតនៅកន្លែងឯករាជ្យ ងាយស្រួលឱ្យប្រជាពលរដ្ឋចូល ធ្វើទំនាក់ទំនង

[1] Research of gtz on the ombudsman in Battambang and Siem Reap, 2007

[2] Evaluation on the Pilot Project Districts of Siem Reap and Battambang on One Window Service, May 2007

- ប្រអប់សំបុត្រ គប្បីដាក់នៅកន្លែងសាធារណៈ ដែលប្រជាពលរដ្ឋងាយមើលឃើញ និងងាយដាក់សំបុត្រ
- ប្រជាពលរដ្ឋ គប្បីត្រូវបានទទួលព័ត៌មានឱ្យបានស៊ីជំរៅពីតួនាទី និងការងាររបស់ការិយាល័យ
- អំប៊ូស្មាន់គប្បីទទួលបាននូវសមត្ថកិច្ច[៣] ។

អង្គការឯករាជ្យមួយចំនួន ដូចជា ADHOC និងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៅកម្ពុជា បានរាយការណ៍ថា ចំនួនបណ្តឹងពីរដ្ឋបាលបានកើនឡើង។ ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋ គឺមានភាពតឹងតែង។ ប្រជាពលរដ្ឋជាច្រើន មិនជឿលើយុត្តិធម៌ ហើយមានការទុកចិត្តតិចតួច លើរដ្ឋបាលសាធារណៈ ទាក់ទិននិង ប្រព័ន្ធយុត្តិធម៌។ គេត្រូវចំណាយច្រើន រងចាំពេលយ៉ាងយូរ ហើយបើសិនជាភាគីម្ខាងទៀតជាអ្នកមាននោះ វាមានភាពពិបាកក្នុងការយកឈ្នះរឿងក្តី។

[3] ibid

## សន្និដ្ឋាន

- គឺជាការចាំបាច់ដែលត្រូវមានដំណើរការប្រព្រឹត្តទៅនៃប្រព័ន្ធទទួលពាក្យបណ្តឹងមួយ ។ ការកើនឡើងនៃចំនួនពាក្យបណ្តឹង បញ្ជាក់ពីសេចក្តីត្រូវការនេះ ។
- ពេលដែលស្ថាប័នកាន់តែឯករាជ្យ នោះការទទួលយកពីប្រជាពលរដ្ឋកាន់តែប្រសើរឡើងដែរ
- ការិយាល័យទទួលពាក្យបណ្តឹង គប្បីងាយស្រួលរក និងស្ថិតនៅកន្លែងអព្យាក្រឹត្យ ។ រឿងនេះក៏ត្រូវបានផ្តល់យោបល់ពីក្រសួងមហាផ្ទៃដែរថា ដើម្បីបង្កើនការទទួលយកនៃ ការិយាល័យនៅបាត់ដំបង "ទីតាំងការិយាល័យ គប្បីស្ថិតនៅឯករាជ្យ ងាយស្រួលឱ្យប្រជាពលរដ្ឋចូលធ្វើទំនាក់ទំនង"[4] ។
- ការងារអនុវត្តន៍ដោយការិយាល័យនេះ ទាក់ទងនឹងបណ្តឹងរបស់ប្រជាពលរដ្ឋពីរដ្ឋបាល មិនទាន់មានតម្លាភាពខ្លាំងនៅឡើយ ។
- ក្រុមការងារនៅក្នុងការិយាល័យទទួលបណ្តឹង គឺជាមន្ត្រីរដ្ឋរបស់ក្រសួង ហើយរដ្ឋមន្ត្រីជាអ្នកពិនិត្យមើលលើបណ្តឹងដែលប្តឹងក្រសួងខ្លួនឯង ។ ទាំងនេះ អាចជាមូលហេតុនៃអ្វីដែលជំនឿ ទុកចិត្តរបស់ប្រជាពលរដ្ឋលើការិយាល័យទទួលពាក្យបណ្តឹងមានកំរិតទាបបើប្រៀបធៀបនឹងគំនិតផ្តួចផ្តើមចង់ឱ្យឯករាជ្យនោះ ។

[4] Evaluation on the Pilot Project Districts of Siem Reap and Battambang on One Window Service, May 2007

## ៣. ទស្សនាទានអំពីអំប៊ុដ្ស្មាន់

### ៣.១ និយមន័យ

អំប៊ុដ្ស្មាន់ គឺជាមន្ត្រីឯករាជ្យ និងមិនលំអៀង ដែលជាទូទៅត្រូវបានផ្តល់ឱ្យតាមរយៈរដ្ឋធម្មនុញ្ញ ដើម្បីត្រួតពិនិត្យមើលរដ្ឋបាល។ អំប៊ុដ្ស្មាន់ ជាអ្នកដោះស្រាយបណ្តឹង របស់សាធារណៈជនប្រឆាំងនឹងភាពអយុត្តិធម៌របស់រដ្ឋបាល និងភាពឆ្គាំឆ្គងរបស់រដ្ឋបាល។ អំប៊ុដ្ស្មាន់ មានអំណាចស៊ើបអង្កេត រៀបចំរបាយការណ៍ និងផ្តល់អនុសាសន៍។ អំប៊ុដ្ស្មាន់ មិនមែនជាចៅក្រម ឬតុលាការទេ។ អំប៊ុដ្ស្មាន់ មិនមានអំណាចដើម្បីបង្គាប់បញ្ជា ឬលុបចោលសកម្មភាពរដ្ឋបាលនោះទេ។ អំណាច និងឥទ្ធិពលរបស់អំប៊ុដ្ស្មាន់ បានមកតែដោយសារ អំប៊ុដ្ស្មាន់ ត្រូវបានតែងតាំងដោយ និងធ្វើរបាយការណ៍ជូនទៅ ស្ថាប័នចម្បងរបស់ជាតិ ដែលជាទូទៅជារដ្ឋសភា ឬ ប្រមុខស្ថាប័ននីតិប្រតិបត្តិ។

អំប៊ុដ្ស្មាន់ ត្រូវបានជ្រើសរើសតាមនីតិវិធីមួយ ដែលជានិមិត្តរូបនៃអព្យាក្រឹត្យភាព និងសេចក្តីថ្លៃថ្នូរ។ អំប៊ុដ្ស្មាន់មានស្វ័យភាព និងត្រូវមានអំណាចស៊ើបអង្កេត ធ្វើអនុសាសន៍ កែលម្អ និងចេញរបាយការណ៍នានា។ អំប៊ុដ្ស្មាន់ ត្រូវបានធានានូវអំណាចក្នុងការផ្ញើរជូនដោយផ្ទាល់នូវរបាយការណ៍របស់ខ្លួន អំពីស្ថានភាពប្រចាំឆ្នាំទៅសភា ឬទៅប្រមុខរដ្ឋ ទៅខេត្តក្រុង... ។ល។

### ៣.២ លក្ខណៈវិនិច្ឆ័យរបស់អំប៊ុដ្ស្មាន់

អំប៊ុដ្ស្មាន់ ធានានូវការស៊ើបអង្កេតត្រឹមត្រូវ និងយុត្តិធម៌ យកចិត្តទុកដាក់ពិចារណាហេតុផលដែលផ្តល់ឱ្យដោយភាគីទាំងពីរ ហើយព្យាយាមសម្រេចឱ្យបាននូវដំណោះស្រាយដ៏ពេញចិត្តមួយ។ លោកសាស្ត្រាចារ្យ Larry B Hill បានរៀបរាប់ពីលក្ខណៈសម្បត្តិរបស់អំប៊ុដ្ស្មាន់ ដែលបរិសុទ្ធនោះដូចខាងក្រោម[៥]:

- គឺត្រូវបានបង្កើតឡើងជាស្ថាប័នដាច់ដោយឡែកមួយ មានដំណើរការស្វ័យត
- ធ្វើប្រតិបត្តិការដោយឯករាជ្យទាំងពីនីតិបញ្ញត្តិ ទាំងពីនីតិប្រតិបត្តិ
- អំប៊ុដ្ស្មាន់ គឺជាមន្ត្រីរដ្ឋាភិបាល ដែលត្រូវបានគេបង្កើតឡើង ស្របច្បាប់
- ជាអ្នកឯកទេសត្រួតពិនិត្យ និងតាមដាន
- ជាអ្នកជំនាញ និងមានវិជ្ជាជីវៈផ្នែករដ្ឋបាល

---

[5] Caiden.G.E., (ed.,), សៀវភៅណែនាំអន្តរជាតិ នៃប្រព័ន្ធអំប៊ុដ្ស្មាន់ Westport, Connectiant; Greenwood Press, 1983, P.13. The author point out that an ombudsman need not be a “he” but can be “she”.

- មិនលំអៀង
- ដែលមានលក្ខណៈបទដ្ឋានសកល
- បំរើអតិថិជន ប៉ុន្តែមិនប្រឆាំងនឹងរដ្ឋបាល
- ប្រជាពលរដ្ឋងាយរក និងទំនាក់ទំនង
- មានលក្ខន្តិៈស្ថាប័នខ្ពស់
- មានធនធានគ្រប់គ្រាន់ដើម្បីបំពេញបេសសកម្មរបស់ខ្លួន

## ៣.៣ តួនាទី និងមុខងាររបស់អំប៊ូស្មាន់

ទស្សនាទានអំប៊ូស្មាន់ គឺផ្តល់ការការពារ ថាប្រជាពលរដ្ឋគ្រប់រូបនឹងទទួលបាននូវមធ្យោបាយដើម្បីបញ្ចេញក្តីបារម្ភណ៏ និងទុក្ខព្រួយរបស់ខ្លួន ជាមួយនឹងឱកាសដើម្បីដោះស្រាយបញ្ហា មុននឹងស្វែងរកអន្តរាគមន៍ពីប្រព័ន្ធតុលាការ ដែលត្រូវការចំណាយច្រើន សាំញ៉ាំ និងកកស្ទះច្រើននោះផង។ មិនផ្លូវការ ចំណាយតិច លឿនអាចបត់បែនបាន មានលទ្ធភាពអនុវត្តនយោបាយថ្មីៗ សេរីពីបទដ្ឋាន និងភស្តុតាងផ្សេងៗ ទាំងនេះគឺជាលក្ខណៈសម្បត្តិដ៏សំខាន់ ដែលធ្វើឱ្យស្ថាប័នអំប៊ូស្មាន់ ជាឧត្តមគតិមួយសម្រាប់មនុស្ស ទូទៅ ស្វែងរកភាពធូរស្រាលតទល់នឹងភាពជ្រុលជ្រួសរបស់រដ្ឋបាល និងធ្វើឱ្យការឈឺចាប់របស់គេ រួមតូច តាមរយៈការដោះស្រាយដោយមិនចំណាយប្រាក់កាស។ តួនាទីរបស់អំប៊ូស្មាន់ គឺធានាថា មន្ត្រី សាធារណៈទាំងអស់បំពេញការងារដោយយុត្តិធម៌ស្មោះត្រង់ និងទទួលខុសត្រូវជាសាធារណៈ។ ដូច្នេះ អំប៊ូស្មាន់ បានក្លាយជាឧបករណ៏តែមួយគត់ តំណាងឱ្យផលប្រយោជន៏របស់ប្រជាពលរដ្ឋ ការពារសិទ្ធិមនុស្សជា មូលដ្ឋាន និងលើកដំកើងគុណភាពរដ្ឋបាលសាធារណៈ។

ការងារស្នូលរបស់អំប៊ូស្មាន់ក្នុងវិស័យសធារណៈ នៅតែជាអ្នកទទួល អ្នកស៊ើបអង្កេត និង ដោះស្រាយបណ្តឹងរបស់ប្រជាពលរដ្ឋដែលទាក់ទិន នឹងភាពមិនប្រក្រតីនៃរដ្ឋបាលរបស់ទីភ្នាក់ងាររដ្ឋាភិបាល ឬ ការបំពេញការងាររបស់គេ។ គោលការណ៏សំខាន់នៃស្ថាប័នអំប៊ូស្មាន់ គឺថា ស្ថាប័ននេះមិនធ្វើការប្រជែងនិង ការងារតុលាការ ឬធ្វើការងារជាស្ថាប័នមួយផ្សេងទៀត ដើម្បីដោះស្រាយលើអ្វីដែលមិនបានដោះស្រាយ ដោយជោគជ័យ នៅក្នុងតុលាការ។ ការងារចម្បងរបស់អំប៊ូស្មាន់ ជាទូទៅគឺអ្នកពិនិត្យ[6]:

- សេចក្តីសម្រេច ដំណើការ អនុសាសន៍ លិខិតបទដ្ឋាននៃការលប់ចោល ឬកម្រៃជើងសារ ដែលផ្ទុយនឹងច្បាប់ ឬបទបញ្ជារ ឬដែលចេញមកពីការអនុវត្ត ឬពីនីតិវិធី លើកលែងតែមិនមានភាពក្លែងបន្លំ ហើយ

[6] បទបញ្ជារបង្កើតការិយាល័យអំប៊ូស្មាន់ Wafaqi Mohtasib ១៩៨៣ បទបញ្ជាប្រធានាធិបតីលេខ ១ ១៩៨៣ (កែប្រែបទបញ្ជាលេខ LXXII ឆ្នាំ ២០០២)

មានហេតុផលត្រឹមត្រូវ ដែលមានផលអាក្រក់ ធ្វើតាមការនឹកឃើញ ឬគ្មានហេតុផល អយុត្តិធម៌ លំអៀង សង្កត់សង្កិន ឬរើសអើងដែល មានមូលដ្ឋានលើភាពមិនប្រក្រតី ឬពាក់ព័ន្ធនឹង ការអនុវត្តអំណាច ឬការបដិសេធមិនធ្វើអ្វីមួយដោយហេតុផលពុករលួយ ឬ មិនមានពីមូលហេតុច្បាស់លាស់ ដូចជា ការសូកប៉ាន់ ពុករលួយ អនុគ្រោះនិយម បក្សពួកនិយម និងការរំលោភផ្នែករដ្ឋបាលជាដើម។

- ភាពខ្ជីខ្ជា ការមិនយកចិត្តទុកដាក់ ការពន្យារពេល អសមត្ថភាព កង្វះប្រសិទ្ធភាព និងភាពមិនយល់ដឹងក្នុងការងាររដ្ឋបាល ឬការមិនទទួលខុសត្រូវចំពោះការងារ និងភារកិច្ចរបស់ខ្លួន។

## ៣.៤ ភាពផ្សេងៗនៃប្រព័ន្ធអំប៊ូស្មាន់

ការិយាល័យអំប៊ូស្មាន់ត្រូវបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ឬដោយអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ ហើយគ្រប់គ្រង ដោយមន្ត្រីសាធារណៈឯករាជ្យជាន់ខ្ពស់ ០១រូប ដែលទទួលខុសត្រូវចំពោះនីតិបញ្ញត្តិ ឬសភា។ អំប៊ូស្មាន់ទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋដែលមានការឈឺចាប់ប្រឆាំងនឹងភ្នាក់ងាររដ្ឋាភិបាល នឹងមន្ត្រីនិយោជក ឬដែលធ្វើការតាមតែអំពើចិត្តខ្លួន។ អំប៊ូស្មាន់មានអំណាចធ្វើការស៊ើបអង្កេត ផ្តល់អនុសាសន៍ដើម្បីកែប្រែ និងចេញជារបាយការណ៍។ អំប៊ូស្មាន់ គឺឯករាជ្យពីរដ្ឋាភិបាល ហើយបំពេញតួនាទី ផ្អែកតែលើការវិនិច្ឆ័យរបស់ខ្លួន។ អំប៊ូស្មានរៀបចំរបាយការណ៍ជូនសភា ពីសកម្មភាព និងការឃ្លាំមើលរបស់ខ្លួន ប៉ុន្តែសភាមិនលូកដៃចូលក្នុងរឿងក្តីនីមួយៗដែលដោះស្រាយដោយ អំប៊ូស្មាន់ នោះឡើយឬក៏ផ្តល់ការងារពិសេសណាឱ្យដោះស្រាយនោះក៏ទេដែរ។

ប្រទេសភាគច្រើនមានអំប៊ូស្មាន់តែមួយ សម្រាប់ការិយាល័យអំប៊ូស្មាន់មួយ។ អំប៊ូស្មាន់ ត្រូវបានតែងតាំងដោយរដ្ឋាភិបាល ឬរដ្ឋសភា។ ប៉ុន្តែនៅទសវត្សក្រោយៗមកនេះ វាមានការប្រែប្រួល ពីព្រោះការិយាល័យអំប៊ូស្មាន់មួយមិនអាចដោះស្រាយបណ្តឹងរបស់ ប្រជាពលរដ្ឋយ៉ាងច្រើនបាននោះទេ គឺមិនមែនដោយសារតែ ការកើនឡើងនូវចំនួនបណ្តឹងនោះទេ តែវាមានការកើនឡើង នូវវិស័យនៃការទទួលខុសត្រូវរបស់អំប៊ូស្មាន់ផងដែរ។ បច្ចុប្បន្ននេះ ប្រទេសជាច្រើន មានប្រព័ន្ធអំប៊ូស្មាន់បែបចំរុះ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងការិយាល័យអំប៊ូស្មាន់តាមវិស័យ ដូចជា អំប៊ូស្មាន់សម្រាប់កុមារ អំប៊ូស្មាន់សម្រាប់ កាលានុវត្តភាពស្មើគ្នា និងអំប៊ូស្មាន់សម្រាប់ជនពិការជាដើម។

**ប្រព័ន្ធអំប៊ូស្មាន់ (១)**

- អំប៊ូស្មាន់នៅ ថ្នាក់ជាតិគឺជាមន្ត្រីដែលបានតែងតាំងដោយរដ្ឋសភា ឬរដ្ឋាភិបាលហើយផ្តល់របាយការណ៍ដោយផ្ទាល់ទៅសភា ឬប្រមុខរដ្ឋាភិបាល
- អំប៊ូស្មាន់នៅថ្នាក់ជាតិក្រោមជាតិ គឺជាមន្ត្រីដែលបានតែងតាំងដោយសភា ឬក្រុមប្រឹក្សានៃករិតពាក់ព័ន្ធណាមួយដូចជា ខេត្ត ក្រុង ហើយរាយការណ៍ដោយផ្ទាល់ទៅស្ថាប័នពាក់ព័ន្ធ ឬក៏ប្រមុខថ្នាក់ដឹកនាំនៃថ្នាក់ក្រោមជាតិនោះ

**ប្រព័ន្ធអំប៊ូស្មាន់ (២)**

- អំប៊ូស្មាន់នៅ ក្នុងក្រសួង គឺជាមន្ត្រីដែលបានតែងតាំងដោយរដ្ឋមន្ត្រី តាមរឿងនីមួយៗ ហើយរាយការណ៍ដោយផ្ទាល់ទៅរដ្ឋមន្ត្រី
- អំប៊ូស្មាន់នៅ សម្រាប់វិស័យទទួលខុសត្រូវណាមួយ គឺ ជាមន្ត្រីដែលបានតែងតាំងដោយរដ្ឋាភិបាល ឬសភា ហើយរាយការណ៍ជូនសភា ឬប្រមុខរដ្ឋាភិបាល




## ៣.៥ ឈ្មោះផ្សេងៗដែលបានប្រើប្រាស់សម្រាប់អំប៊ូស្មាន់

មានឈ្មោះជាច្រើនត្រូវបានប្រើប្រាស់ដើម្បីសំគាល់ពីការិយាល័យអំប៊ូស្មាន់ នៅក្នុងប្រទេសផ្សេងៗ។ ឈ្មោះដែលបានប្រើប្រាស់ដោយប្រទេសទាំងនោះ បង្ហាញឱ្យឃើញពីភាពប្លែកគ្នានៃទម្រង់ និងវិស័យនៃការិយាល័យនេះ។

## អំប៊ុដ្សមាន់ និងឈ្មោះផ្សេងៗទៀត

ពាក្យ "អំប៊ុដ្សមាន់" (Ombudsman) មានប្រភពពីភាសាស៊ុយអែត និងមានន័យថា "តំណាង"។ មានឈ្មោះជាច្រើនត្រូវបានប្រើប្រាស់ដើម្បីសំគាល់ការិយាល័យអំប៊ុដ្សមាន់ នៅតាមបណ្តាប្រទេសផ្សេងៗ ដែលបានអនុវត្តការិយ៉ាយអំប៊ុដ្សមាន់នេះ ដូចជា:

- **Defensor del Pueblo** ជាឈ្មោះការិយាល័យអំប៊ុដ្សមាន់នៅតាមប្រទេសមួយចំនួនធំដែលនិយាយភាសាអេស្បាញ ដូជា ប្រទេសអេស្បាញ អាហ្សង់ទិន ប៉េរូ និងកូឡុមប៊ីជាដើម។
- **Parliamentary Commissioner for Administration** (ស្នងការសភាសំរាប់រដ្ឋបាលស៊ីវិលង្កា អង់គ្លេស)
- **Médiateur de la République** អ្នកសម្រុះសម្រួលរបស់សាធារណៈរដ្ឋ (បារាំង កាបុង ម៉ូរីតានី សេណេកាល)
- **Public Protector** អ្នកការពារសាធារណៈជន (អាហ្វ្រិកខាងត្បូង)
- **Protecteur du Citoyen** អ្នកការពារប្រជាពលរដ្ឋ (កេបិច)
- **Volksanwaltschaft** (អូទ្រីស)
- **Public Complaints Commission** គណៈកម្មការទទួលពាក្យបណ្តឹងសាធារណៈ (នីហ្សេរីយ៉ា)
- **Provedor de Justiça** (ព័រទុយកាល)
- **Difensore Civico** (អ៊ីតាលី)
- **Investigator-General** អគ្គស៊ើបអង្កេត (ស៊ីមបាវ៉េ)
- **Citizen's Aide** ជំនួយសម្រាប់ប្រជាពលរដ្ឋ (អ៊ីយូវ៉ា)
- **Wafaqi Mohtasib** (ប៉ាគីស្ថាន), **Lok Ayukta** (ឥណ្ឌា)។

ព័ត៌មានបន្ថែមពីប្រវត្តិ នៃអំប៊ុដ្សមាន់ និងប្រព័ន្ធអំប៊ុដ្សមាន់របស់ប្រទេសនីមួយៗ ដែលបានអនុវត្ត អាចរកបាននៅក្នុងរបាយការណ៍ ប្រព័ន្ធអំប៊ុដ្សមាន់ និងប្រព័ន្ធទទួលពាក្យបណ្តឹងផ្សេងៗ ដែលចងក្រងដោយ អង្គការហ្ស៊ីឌីហ្សេត នៃកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ និងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅក្នុងខែកញ្ញា ឆ្នាំ ២០០៨។

## ៤. គំនិតដំបូងៗអំពី "អំប៊ុដស្មាន់" នៅកម្ពុជា

### ៤.១ ជំរើសទី ១

ការិយាល័យជាតិទទួលបណ្តឹងមួយត្រូវបានបង្កើតឡើង ដើម្បីទទួលបន្ទុករាល់ពាក្យបណ្តឹងទាំងអស់ ដោយឯករាជ្យ លើពាក្យបណ្តឹងទាំងឡាយ ដែលបានប្តឹងដោយផ្ទាល់ប្រឆាំងនឹងមន្ត្រីរាជការ ពីបណ្តាក្រសួង ឬពីរដ្ឋបាលរាជធានី ខេត្តក្រុង ស្រុកខ័ណ្ឌ។

ប្រមុខនៃការិយាល័យជាតិទទួលបណ្តឹង ត្រូវបានជ្រើសរើសដោយ សភា និងគណៈរដ្ឋមន្ត្រី ហើយមានសិទ្ធិធ្វើអនុសាសន៍។

ការិយាល័យជាតិនេះ មានសមត្ថកិច្ចទូលំទូលាយ ដែលក្នុងនោះសិទ្ធិធ្វើការស៊ើបអង្កេត ធ្វើអធិការកិច្ចលើឯកសារផ្សេងៗ និងមានគោលនយោបាយព័ត៌មានឯករាជ្យមួយ។

ការិយាល័យនេះ ទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួន យ៉ាងហោចណាស់ ១ដង ក្នុងមួយឆ្នាំ នៅមុខសភា។ រដ្ឋាភិបាល និងក្រសួងផ្សេងៗទទួលរបាយការណ៍ប្រចាំឆ្នាំ ពីការិយាល័យនេះ។ របាយការណ៍ មានលក្ខណៈសាធារណៈ នឹងអាចឱ្យប្រព័ន្ធផ្សព្វផ្សាយរកបាន។

បណ្តឹងដែលបានចុះបញ្ជីនៅតាមក្រសួងនីមួយៗ ត្រូវបញ្ជូនទៅការិយាល័យជាតិទទួលបណ្តឹងនេះ។

ចាប់ផ្តើមពី ឆ្នាំ ២០០៩ ការិយាល័យប្រជាពលរដ្ឋនៅបាត់ដំបង ដែលបានជ្រើសរើសឡើងដើម្បីធ្វើការនៅក្នុងក្រុងផ្សេងៗ ដោយមានជំនួយពីធនាគារពិភពលោក នឹងទទួលបានសមត្ថកិច្ចទូលំទូលាយដូចដែលមានចែងក្នុងប្រកាសលេខ ៧៩០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ការិយាល័យប្រជាពលរដ្ឋនៅបាត់ដំបង និងសៀមរាប។

ការិយាល័យជាតិទទួលបណ្តឹង ក៏ដូចជាការិយាល័យប្រជាពលរដ្ឋថ្នាក់ស្រុក ត្រូវស្ថិតនៅក្នុង "ទីតាំងអព្យាក្រឹត្យ"។

ការិយាល័យជាតិទទួលបណ្តឹង មានប្រព័ន្ធទាន់ហេតុការណ៍មួយ ដែលអាចឱ្យប្រជាពលរដ្ឋប្តឹង និងបញ្ជូនទៅប្រមុខប្រធានការិយាល័យជាតិទទួលបណ្តឹង។

### ៤.២ ជំរើសទី ២

ការិយាល័យជាតិទទួលបណ្តឹង ត្រូវបានបង្កើតឡើង (សូមមើលជំរើសទី ១) ហើយការិយាល័យ ទទួលបណ្តឹង នៅតាមក្រសួងនិមួយៗក៏ត្រូវបានពង្រីកជាលំដាប់ជាមួយគ្នាផងដែរ។ ប្រធាននៃការិយាល័យទទួលបណ្តឹងត្រូវជ្រើសរើសដោយគណៈរដ្ឋមន្ត្រី។

ការិយាល័យទទួលបណ្តឹង ត្រូវមានសិទ្ធិធ្វើការស្រាវជ្រាវស៊ើបអង្កេត រឿងក្តីដោយឯករាជ្យ ហើយមានសិទ្ធិពិនិត្យមើលឯកសារ និងធ្វើការផ្សព្វផ្សាយដោយឯករាជ្យ ។

ការិយាល័យទទួលបណ្តឹងនៅតាមក្រសួង ត្រូវស្ថិតនៅក្រៅក្រសួង ក្នុងកន្លែង អព្យាក្រឹត្យ បើសិនជាអាចការិយាល័យទទួលបណ្តឹងទាំងអស់ត្រូវស្ថិតនៅកន្លែងតែមួយ ។

ការិយាល័យទទួលពាក្យបណ្តឹងតាមវិស័យ ត្រូវធ្វើរបាយការណ៍ ០១ ឆ្នាំ ម្តង ជូន មុខគណៈរដ្ឋមន្ត្រី។ សមាជិកសភា និងប្រមុខការិយាល័យទទួលពាក្យបណ្តឹងជាតិ ទទួលរបាយការណ៍ប្រចាំឆ្នាំ ពីការិយាល័យជាតិទទួលបណ្តឹងផ្សេងៗរបស់ក្រសួង ។

## ៤.៣ ជំរើសទី ៣

ការិយាល័យជាតិទទួលពាក្យបណ្តឹង ត្រូវបានបង្កើត( សូមមើលជំរើសទី ១) ។ បន្ថែមលើនេះ ការិយាល័យទទួលបណ្តឹង ត្រូវមានក្រុមប្រឹក្សាមួយ ។ ក្រុមប្រឹក្សាមានសិទ្ធិសម្រុះសម្រួលរឿងក្តី ហើយ រៀបចំអនុសាសន៍ បើសិនភាគីទាំងពីរ ( រដ្ឋបាល និងប្រជាពលរដ្ឋ) យល់ព្រម ។

ក្រុមប្រឹក្សាមានសមាជិកមកពីសភា អ្នកជំនាញរដ្ឋបាល តំណាងសម្ព័ន្ធជាតិ តំណាងសភាពាណិជ្ជកម្ម តំណាងអង្គការក្រៅរដ្ឋាភិបាល ។ ប្រធានក្រុមប្រឹក្សា គឺជាប្រធានការិយាល័យជាតិទទួលបណ្តឹងនេះ ។

## ៤.៤ ឈ្មោះការិយាល័យទទួលពាក្យបណ្តឹង

ផ្អែកលើបទពិសោធន៍ពីការិយាល័យប្រជាពលរដ្ឋនៅបាត់ដំបង ពាក្យខ្មែរសម្រាប់ពាក្យ អំប៊ុដស្មាន់ ថា **ការិយាល័យប្រជាពលរដ្ឋនោះ** មិនបានបញ្ជាក់ន័យឱ្យបានច្បាស់ពីសេវាដែលការិយាល័យនេះផ្តល់ទេ ។ ការនេះអាចជា មូលហេតុមួយដែល ការិយាល័យនេះមិនសូវមានអ្នកមកប្តឹង ។

ដូច្នេះ វាជាការចាំបាច់ដែលថា ឈ្មោះដែលត្រូវបង្កើតសម្រាប់ការិយាល័យ សម្រាប់មន្ត្រីដែលទទួលបន្ទុកនេះ ត្រូវតែបង្ហាញពីការទទួលខុសត្រូវ របស់ស្ថាប័ន ឬមន្ត្រីនេះ ថាតើធ្វើអ្វី ។ ឧទាហរណ៍ អាចជា ការិយាល័យជំនួយប្រជាពលរដ្ឋ ទីប្រឹក្សាសម្រាប់ប្រជាពលរដ្ឋ អ្នកការពារប្រជាពលរដ្ឋ គណៈកម្មការទទួលបណ្តឹងសាធារណៈ អាជ្ញាធរជាតិទទួលបន្ទុកបណ្តឹងសាធារណៈ ជាដើម ។

## ៥ ការសន្និដ្ឋានចុងក្រោយ

ប្រព័ន្ធដំណើការទទួលបណ្តឹង អាចដើរតួនាទីយ៉ាងសំខាន់ ដើម្បីបង្កើនការទុកចិត្តរបស់ប្រជាពលរដ្ឋ លើរដ្ឋបាលសាធារណៈ និងរដ្ឋាភិបាលកម្ពុជា។ លក្ខណៈតំរូវ គឺថាស្ថាប័ននេះ :

- អាចធ្វើប្រតិបត្តិការបានដោយសេរី មិនទទួលឥទ្ធិពលនយោបាយ
- មានឯករាជ្យភាពពិតប្រាកដ
- ធ្វើការសម្រុះសម្រួលរឿងក្តីដោយយុត្តិធម៌
- មិនប្រព្រឹត្តលើជនណាមួយ ប្រសើរជាង ឬអាក្រក់ជាងជនណាមួយទៀតនោះឡើយ។

ប្រមុខការិយាល័យនេះ ត្រូវការនូវបុគ្គលិក និងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីធ្វើការដោយស្វ័យភាពលើការទទួលខុសត្រូវរបស់ខ្លួន ហើយទទួលបាននូវការគាំទ្រដោយឥតសំចៃពីសភា រដ្ឋាភិបាល និងក្រសួង។